ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

**ធនាគារជាតិ នៃ កម្ពុជា**

លេខ ធ៥...០១៧...៤១៥...គ.ស-ក

# សេចក្ដីជូនដំណឹង
## ស្ដីពី
## ការបង្កើនឥណប្រតិទានប្រតិបត្តិការផ្ដល់សន្ទនីយភាពដោយមានការធានា (LPCO)

ធនាគារជាតិនៃកម្ពុជា មានកិត្តិយសសូមជម្រាបជូនជាដំណឹងដល់ គ្រឹះស្ថានធនាគារនិងមីក្រូហិរញ្ញវត្ថុទាំងអស់ជ្រាបថា ឥណប្រតិទានប្រតិបត្តិការ LPCO នឹងមានការបង្កើន ពី ៣ខែ ទៅ ១ឆ្នាំ (៣៦៤ថ្ងៃ) ដើម្បីឆ្លើយតបទៅនឹងតម្រូវការសន្ទនីយភាពរយៈពេលវែង របស់គ្រឹះស្ថានធនាគារនិងមីក្រូហិរញ្ញវត្ថុ។ LPCO ដែលមានឥណប្រតិទានរយៈពេល១ឆ្នាំនេះ នឹងអនុវត្តចាប់ពីថ្ងៃជូនដំណឹងនេះតទៅ។

គ្រឹះស្ថានធនាគារនិងមីក្រូហិរញ្ញវត្ថុ ដែលមានបំណងចូលរួមក្នុងប្រតិបត្តិការ LPCO សូមត្រៀមលក្ខណៈចូលរួមដេញថ្លៃនៅថ្ងៃទី២៣ ខែឧសភា ឆ្នាំ២០១៧ ខាងមុខនេះ។

សេចក្ដីដូចបានជម្រាបជូនខាងលើ សូមគ្រឹះស្ថានធនាគារនិងមីក្រូហិរញ្ញវត្ថុទាំងអស់ជ្រាបជាព័ត៌មាន។

រាជធានីភ្នំពេញ ថ្ងៃទី១៩ ខែឧសភា ឆ្នាំ២០១៧
**អគ្គនាយកបច្ចេកទេស**

ជា សិរី

សូមទំនាក់ទំនងមកធនាគារជាតិនៃកម្ពុជា
អគ្គនាយកដ្ឋានបច្ចេកទេស
នាយកដ្ឋានប្រតិបត្តិការ
អ៊ីម៉ែល៖ lpco_info@nbc.org.kh